ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤០ សសរ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដោះស្រាយ រាល់បាតុភាព ដែលទាក់ទងដល់អតីតបុរីកម្មករអគ្គិសនីក្បាលថ្នល់ ស្ថិតក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដោះស្រាយរាល់បាតុភាព ដែលទាក់ទងដល់អតីតបុរីកម្មករអគ្គិសនីក្បាលថ្នល់ ស្ថិតក្នុងរាជធានីភ្នំពេញ ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សក់ សេដ្ឋា** | អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២-លោក | **សែ សុវណ្ណ** | ប្រធាននាយកដ្ឋានសំណង់ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ | ជាអនុប្រធាន |
| ៣-លោកបណ្ឌិត | **តិច សំណាង** | ជំនួយការឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៤-លោក | **ឈួន សុធី** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ | ជាសមាជិក |
| ៥-លោក | **អៀម ចយ** | អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ | ជាសមាជិក |

| | | | |
|---|---|---|---|
| ៦-លោក | សៀង ឈុ ន្ធី | អនុប្រធាននាយកដ្ឋាននីតិកម្មក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧-លោក | ជ័យ សារឿន | អភិបាលខ័ណ្ឌចំការមន | ជាសមាជិក |
| ៨-លោក | ម៉ើន ទុន្ធី | អនុប្រធានការិយាល័យគ្រប់គ្រងខេត្ត-ក្រុង ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៩-លោក | ហួន សុវណ្ណ | មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ច ដូចតទៅ :

-ចុះសិក្សាស្រាវជ្រាវអំពីទំហំផ្ទៃដី របស់អតីតបុរីកម្មករអគ្គិសនី

-សិក្សាស្រាវជ្រាវ អំពីស្ថិតិប្រជាពលរដ្ឋដែលរស់នៅក្នុងអគារនីមួយៗ និងប្រជាពលរដ្ឋដែលមានលំនៅដ្ឋានក្នុងបរិវេណបុរីកម្មករអគ្គិសនី

-រកវិធានការដោះស្រាយជាមួយសហគមន៍ ឬ តំណាងប្រជាពលរដ្ឋអោយបានឆាប់ ទោះបីជាមធ្យោបាយណាក៏ដោយ

-ធ្វើរបាយការណ៍សរុប អំពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៤ :** សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៥
-ឯកសារ-កាលប្បវត្តិ